# I- ទីស្តីការគណៈរដ្ឋមន្ត្រី

## ១- អនុក្រឹត្យ

*រាជធានីភ្នំពេញ , ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ១៩៩៥*

**អនុក្រឹត្យលេខ ៣៦ អនក្រ**
**ស្តីពីការបង្កើតគណៈកម្មាធិការជាតិអចិន្ត្រៃយ៍**
**ប្រឡងប្រណាំងកែលំអសោភ័ណភាព ខេត្ត-ក្រុង**
**ទូទាំងប្រទេស**

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-យោងតាមសារាចរលេខ ០២ ស.រ ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការប្រឡងប្រណាំងកែលំអសោភ័ណភាព ខេត្ត-ក្រុង ទូទាំងប្រទេស

**សំរេច**

**មាត្រា ១ :** បង្កើតគណៈកម្មាធិការជាតិអចិន្ត្រៃយ៍ប្រឡងប្រណាំងកែលំអសោភ័ណភាព ខេត្ត-ក្រុង ទូទាំងប្រទេស ដែលមានសមាសភាពដូចតទៅ ÷

១- ឯកឧត្តម សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ — សហប្រធាន

២- ឯកឧត្តមរដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី — អនុប្រធានអចិន្ត្រៃយ៍

៣- ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងអភិវឌ្ឍន៍ជនបទ — សមាជិក

៤- ឯកឧត្តមរដ្ឋលេខាធិការ ក្រសួងទេសចរណ៍ — សមាជិក

៥- ឯកឧត្តមអនុរដ្ឋលេខាធិការ ក្រសួងគ្រប់គ្រងបរិដ្ឋាន — សមាជិក

www.pheakdeylaw.com

៦- ឯកឧត្តមអនុរដ្ឋលេខាធិការ ក្រសួងសាធារណការនិងដឹកជញ្ជូន សមាជិក

៧- ឯកឧត្តមអនុរដ្ឋលេខាធិការ ក្រសួងសុខាភិបាល សមាជិក

៨- ឯកឧត្តមអនុរដ្ឋលេខាធិការ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ សមាជិក

៩- ឯកឧត្តមអភិបាលគ្រប់ខេត្ត-ក្រុង សមាជិក

១០- លោកប្រធាននាយកដ្ឋានប្រលងប្រណាំង ទីស្តីការគណៈរដ្ឋមន្ត្រី លេខាធិការ

**មាត្រា ២ :** គណៈកម្មាធិការជាតិនេះមានភារកិច្ចដូចខាងក្រោម ÷

-កសាងលក្ខខ័ណ្ឌនានាសំរាប់ការវាស់ស្ទង់ និង ផ្តល់ពិន្ទុដល់ការងារប្រលងប្រណាំងទូទាំងប្រទេស ។

-ពិនិត្យតាមដាន វាយតំលៃនូវលទ្ធផលប្រឡងប្រណាំងដែលខេត្ត-ក្រុង សំរេចបាន ។

-កសាងសំណុំលិខិតលើកសំណើជូនរាជរដ្ឋាភិបាល ដើម្បីផ្តល់គ្រឿងឥស្សរិយយស និង រង្វាន់ផ្សេងៗក្នុងការងារនេះ ។

-ប្រជុំបូកសរុបរបាយការណ៍របស់ខេត្ត-ក្រុង ប្រចាំឆមាសនិងឆ្នាំ ហើយរាយការណ៍ជូនគណៈរដ្ឋមន្ត្រីព្រមជាមួយ នេះរៀបចំបើកសន្និបាតប្រចាំឆ្នាំ បូកសរុបស្នាដៃ និង លើកពីសោធន៍តំរូសំរាប់ទិសដៅនាឆ្នាំខាងមុខ ។

គណៈកម្មាធិការជាតិ មានសិទ្ធិបែងចែកតំបន់ប្រឡងប្រណាំងក្នុងព្រះរាជាណាចក្រកម្ពុជា និងមានសិទ្ធិបង្កើតលេខាធិការដ្ឋានអចិន្ត្រៃយ៍ដើម្បីជួយការងារ ។

**មាត្រា ៣ :** សមាជិកគណៈកម្មាធិការជាតិ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន និង មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងមហាផ្ទៃ ។

**មាត្រា ៤ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និង ឯកឧត្តម-អស់លោក ដែលមានឈ្មោះក្នុងមាត្រា ១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១
ព្រះហស្តលេខានិងត្រា
**នរោត្តម រណឫទ្ធិ**

នាយករដ្ឋមន្ត្រីទី ២
ហត្ថលេខានិងត្រា
**ហ៊ុន សែន**

* * *

www.pheakdeylaw.com